# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦. សរាចរ

# សារាចរណែនាំ
## ស្តីពី
## ការទប់ស្កាត់ និងលុបបំបាត់ការលួចបន្លំ ស្បៀងពលកម្មរបស់អង្គការស្បៀងអាហារពិភពលោក

កន្លងមករាជរដ្ឋាភិបាលបានកត់សំគាល់ឃើញថា អង្គការស្បៀងអាហារពិភពលោក WFP និង សហគមន៍អន្តរជាតិ បានអនុវត្តគំរោងក្នុងការផ្តល់ជំនួយស្បៀងពលកម្មដល់ប្រជាពលរដ្ឋ ដែលខ្វះខាតស្បៀង អាហារនៅទូទាំងប្រទេស តាមរយៈការស្តារ និងស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាអាទិ៍ៈ កសាង ផ្លូវលំ ដីកស្រះ និងស្តារប្រព័ន្ធធារាសាស្ត្រ ខ្នាតតូច និងមធ្យម សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម នឹង ការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋនៅទីជនបទ ។

ប៉ុន្តែ ទន្ទឹមនឹងការប្រើប្រាស់ជំនួយរបស់អង្គការស្បៀងអាហារពិភពលោក ដែលទទួលបានលទ្ធផលគួរ ជាទីមោទនៈនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញមាន បាតុភាពអសកម្មកើតឡើងគួរឱ្យព្រួយបារម្ភ ចំពោះ សាធារណមតិជាតិ និងអន្តរជាតិ ដែលក្នុងនោះបាតុភាពលេចធ្លោ មានការឃុបឃិតគ្នាលួចបន្លំយកស្បៀងពលកម្ម ដែលជាជំនួយមនុស្សធម៌របស់អង្គការស្បៀងអាហារពិភពលោក និងសហគមន៍អន្តរជាតិ ក្រោមរូបភាពលួចបំប៉ោង បរិមាណទំហំផ្ទៃក្រឡា និងចំនួនពលករ ដែលបានចូលរួមស្តារហេដ្ឋារចនាសម្ព័ន្ធនីមួយៗ ឬក្រោមរូបភាពផ្សេងៗ ទៀត ដើម្បីយកទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មន្ត្រី និងជនខិលខូចមួយចំនួន ។

ដើម្បីដោះស្រាយនូវបាតុភាពអសកម្មខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការចាំបាច់ចំពោះមុខ ជាបន្ទាន់ និងសូមធ្វើការណែនាំដូចតទៅ :

១-អង្គភាពប្រឆាំងអំពើពុករលួយ នៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវសហការជាមួយអង្គការស្បៀង អាហារពិភពលោក និងអាជ្ញាធរដែនដី ដើម្បីចុះស្រាវជ្រាវអោយបានហ្មត់ចត់ និងរកឱ្យឃើញនូវជនល្មើស ក្នុង ការលួចបន្លំស្បៀងពលកម្ម ដែលជាជំនួយមនុស្សធម៌របស់កម្មវិធីស្បៀងអាហារពិភពលោក សំរាប់ចែកជូន ប្រជាពលរដ្ឋក្នុងការធ្វើពលកម្ម កសាង ហេដ្ឋារចនាសម្ព័ន្ធ ដូចជាស្ថាបនាផ្លូវលំ ជីកស្រះ លើកទំនប់ប្រព័ន្ធ ធារាសាស្ត្រតូច និងមធ្យម និងឧបត្ថម្ភដល់ សិស្សានុសិស្ស និងជនក្រីក្រងាយរងគ្រោះ នៅតាមមូលដ្ឋាន ភូមិ ឃុំ សាលារៀន មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកតាមស្រុក ខណ្ឌ ដើម្បីមានវិធានការតាមច្បាប់ជាធរមាន ។

ចំពោះមន្ត្រីរាជការណាដែលបានប្រព្រឹត្តបទល្មើសលួចបន្លំស្បៀងពលកម្ម និង ស្បៀងជាជំនួយ ឧបត្ថម្ភរបស់អង្គការស្បៀងអាហារពិភពលោក និងសហគមន៍អន្តរជាតិ ដើម្បីបំរើឱ្យផលប្រយោជន៍បក្សពួក ផ្ទាល់ខ្លួន ក្រសួង ស្ថាប័នសាមីនីមួយៗ ត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល និងត្រូវមានវិធានការរដ្ឋបាល និងសងសំណងនូវការបាត់បង់ស្បៀងជូនរដ្ឋវិញ ហើយក្នុងករណីធ្ងន់ធ្ងរ ត្រូវកសាងសំណុំរឿងបញ្ជូនជនល្មើសទៅ តុលាការ ដើម្បីធ្វើការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។

២-ក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អំពីការធ្វើសំណើសុំស្បៀងពលកម្ម ឬជំនួយឧបត្ថម្ភជូនប្រជាពលរដ្ឋក្រីក្រ ខ្វះខាតស្បៀង និងជនងាយរងគ្រោះ ចាស់ជរា គ្មានទីពឹង ធ្វើគំរោងឱ្យបានរលូន ស្មោះត្រង់ និងពិតប្រាកដ ចៀសវាងការលួចបំប៉ោងតួលេខ ផ្ទៃក្រឡា ឬចំនួនពលករ ដោយធ្វើសំណើសុំស្បៀងលើសពីចំនួនពិត ដែលត្រូវការជាក់ស្តែងសំរាប់ចែកឱ្យអ្នកធ្វើពលកម្ម ឬចំនួនសិស្សានុសិស្ស អ្នកជំងឺ និងជនក្រីក្រផ្សេងទៀត ដោយខិតខំចៀសវាងនូវការលាក់បន្ទំ ព្រមទាំងចែកចាយស្បៀងដែលលើសទៅឱ្យអ្នកផ្សេងទៀត ខុសពីគោលដៅ ។

៣-ក្រសួងអភិវឌ្ឍជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវធ្វើការអប់រំ និងណែនាំដល់មន្ត្រីរាជការក្រោមឱវាទដែលទទួលការងារអនុវត្តគំរោងពាក់ព័ន្ធនឹងការទទួលប្រើប្រាស់ស្បៀងពលកម្ម និង ជំនួយឧបត្ថម្ភដល់សិស្សានុសិស្ស ប្រជាពលរដ្ឋក្រីក្រខ្វះខាតស្បៀង ឱ្យបង្កើននូវស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានានូវការជឿទុកចិត្តពីអង្គការស្បៀងអាហារពិភពលោក និងសហគមន៍អន្តរជាតិ ចំពោះរាជរដ្ឋាភិបាល ក្នុងការបន្តផ្តល់ជំនួយស្បៀងពលកម្ម ដើម្បីជួយឧបត្ថមឱ្យបានដល់ដៃប្រជាពលរដ្ឋក្រីក្រពិតប្រាកដតទៅទៀត ។

៤-ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដី ត្រូវបង្កើនកិច្ចសហការជាមួយអង្គការស្បៀងអាហារពិភពលោក និងតំណាងបណ្តាប្រទេសជាម្ចាស់ជំនួយឱ្យបានល្អ ដើម្បីកសាងភាពជាដៃគូ ក្នុងការទទួល និងផ្តល់ជំនួយស្បៀងឱ្យបានកាន់តែច្រើនថែមទៀត ជូនដល់ដៃសិស្សានុសិស្ស ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ។

៥-ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់កម្មវិធីជាកំណត់ក្នុងការជួបប្រជុំគ្នា ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ អំពីកម្មវិធីស្បៀងអាហារនេះឱ្យបានញឹកញាប់ ជាមួយអង្គការស្បៀងអាហារពិភពលោក អង្គការអន្តរជាតិ និងប្រទេសផ្តល់ជំនួយ ដើម្បីពិភាក្សាអំពីការកំណត់រៀបចំឡើងវិញនូវគោលការណ៍រួម និងរចនាសម្ព័ន្ធស្តីពី ការគ្រប់គ្រង និង ការប្រើប្រាស់ស្បៀងពលកម្ម របស់អង្គការស្បៀងអាហារពិភពលោក សំដៅឱ្យការប្រើប្រាស់ជំនួយនេះបានសមស្រប និងចំគោលដៅ និងធានាមិនឱ្យមានការបាត់បង់ស្បៀងដូចរយៈពេលកន្លងមក ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី ត្រូវធ្វើការផ្សព្វផ្សាយអប់រំជូនដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ឱ្យបានយល់ជ្រួតជ្រាប និងទទួលអនុវត្តឱ្យបានសំរេចលទ្ធផលជាវិជ្ជមាន ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

sothu29-6-04